ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
លេខ : ០០៦ សណន

# សេចក្តីណែនាំ
# ស្តីពី
# បែបបទ នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

២០២៤

មាតិកា

# សេចក្តីណែនាំលេខ ០០៦ សណន ស្តីពី
# បែបបទ និងនីតិវិធីនៃការកែតម្រូវទិន្នន័យ និង
# មោឃភាពបញ្ជីអត្រានុកូលដ្ឋាន


| |
|---|
| **I.អំពីទិន្នន័យដែលអាចកែតម្រូវបាន និងការមោឃភាពបញ្ជីអត្រានុកូលដ្ឋាន** |
| ១.ទិន្នន័យដែលអាចកែតម្រូវបាន |
| ២.ការមោឃភាពបញ្ជីអត្រានុកូលដ្ឋាន |
| **II.សមត្ថកិច្ចក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន** |
| **III.នីតិវិធីក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន** |
| **១.នៅក្នុងផ្ទាំកំពុងអនុវត្ត** |
| ១.១. ការកែតម្រូវលើកំហុសទិន្នន័យដែលអាចកែតម្រូវបាន |
| ១.២.ការមោឃភាពលើបញ្ជីអត្រានុកូលដ្ឋានដែលមិនអាចកែតម្រូវបាន |
| **២.នៅក្នុងផ្ទាំកន្លងផុត** |
| **២.១.ការដាក់ពាក្យ និងទីកន្លែងស្នើសុំ** |
| **២.២.ឯកសារភ្ជាប់** |
| **២.៣.ការសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** |
| **២.៤.ការអនុវត្តសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** |
| **IV.នីតិវិធីនៃការកែតម្រូវទិន្នន័យនិងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ** |
| **១.នៅក្នុងផ្ទាំកំពុងអនុវត្ត** |
| **១.១.ការដាក់ពាក្យ និងទីកន្លែងស្នើសុំ** |
| **១.២.ឯកសារភ្ជាប់** |
| **១.៣.ការអនុវត្តសេចក្តីសម្របស់តុលាការនៅរដ្ឋបាលឃុំ សង្កាត់** |
| **២.នៅក្នុងផ្ទាំកន្លងផុត** |
| **២.១.ការដាក់ពាក្យ និងទីកន្លែងស្នើសុំ** |
| **២.២.ឯកសារភ្ជាប់** |
| **២.៣.ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ** |
| **ក.សមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** |
| **ខ.សមត្ថកិច្ចរបស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** |

| |
|---|
| ឧបសម្ព័ន្ធទី១ ពាក្យស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន |
| ឧបសម្ព័ន្ធទី២ ពាក្យស្នើសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋាន |
| ឧបសម្ព័ន្ធទី៣ បញ្ជីអត្រានុកូលដ្ឋានបានកែតម្រូវ |
| ឧបសម្ព័ន្ធទី៤ បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព |
| ឧបសម្ព័ន្ធទី៥ ពាក្យស្នើសុំកែតម្រូវទិន្នន័យនិងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ |
| ឧបសម្ព័ន្ធទី៦ បញ្ជីអត្រានុកូលដ្ឋាននេះបានកែតម្រូវ |
| ឧបសម្ព័ន្ធទី៧ បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព |
| ឧបសម្ព័ន្ធទី៨ ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ |
| ឧបសម្ព័ន្ធទី៩ ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ |

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ៖ ...០០៦...សណន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីណែនាំ
## ស្ដីពី
## បែបបទ នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវកន្លងមក ក្រសួងមហាផ្ទៃបានរកឃើញថា ប្រជាពលរដ្ឋខ្មែរមួយចំនួនបាននិងកំពុងជួបបញ្ហាប្រឈមលើកំហុសទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជី និងសំបុត្រអត្រានុកូលដ្ឋានជាមួយឯកសារអត្តសញ្ញាណដទៃទៀត។ ទន្ទឹមនឹងនេះ ប្រជាពលរដ្ឋខ្លះបានចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទតែមួយលើសពីមួយដង ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋទាំងនោះជួបការលំបាកនៅក្នុងការស្នើសុំ សេវារដ្ឋបាលផ្សេងៗ។ ពាក់ព័ន្ធបញ្ហានេះ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ បានដាក់ចេញនូវអនុក្រឹត្យនិងលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋឱ្យទទួលបានសេវាកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដែលខុសឆ្គង ឬបញ្ជីអត្រានុកូលដ្ឋានដែលចុះជាន់គ្នា ឱ្យបានឆាប់រហ័ស ទូលំទូលាយ និងងាយស្រួល ក្នុងគោលបំណងសម្រេចបានគោលដៅ "**មនុស្សម្នាក់មានអត្តសញ្ញាណតែមួយ**" ស្របតាមផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃបានសង្កេតឃើញថា ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ និងសេចក្តីសម្រេចរបស់តុលាការ ដែលអនុវត្តនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មួយចំនួនតូចមិនទាន់ដំណើរការបានល្អគ្រប់ជ្រុងជ្រោយនៅឡើយ។

ដើម្បីជួយសម្រួលដល់ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ឱ្យកាន់តែមានប្រសិទ្ធភាពសំដៅឆ្លើយតបទៅនឹងសំណូមពរ និងតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ **ក្រសួងមហាផ្ទៃ** បានសម្រេចដាក់ចេញនូវសេចក្តីណែនាំថ្មី ស្តីពីបែបបទ នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ជំនួសសេចក្តីណែនាំលេខ០៤៥ សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ដូចខាងក្រោម៖

### I. អំពីទិន្នន័យដែលអាចកែតម្រូវបាន និងការមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

#### ១. ទិន្នន័យដែលអាចកែតម្រូវបាន

ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានដែលអាចកែតម្រូវបាន គឺជាទិន្នន័យដែលបានសរសេរខុស ឬភាន់ច្រឡំព័ត៌មាន ឬខកខានមិនបានបំពេញព័ត៌មាន (កំហុសបច្ចេកទេស) ដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម៖

- ការខុសឆ្គងអក្ខរាវិរុទ្ធលើ នាមត្រកូល និង/ឬនាមខ្លួន "ជាអក្សរខ្មែរ" និង "អក្សរឡាតាំង" របស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយ (មានន័យថាសូរសំឡេងដូចគ្នា ឬប្រហាក់ប្រហែលគ្នាប៉ុន្តែការសរសេរខុសគ្នា ឬមានកំហុសផ្សេងទៀត)

- ការសរសេរខុស "ភេទ" នៅពេលចុះបញ្ជីដូចជាភេទ "ប្រុស" តែសរសេរដាក់ថាភេទ "ស្រី" ឬភេទ "ស្រី" តែសរសេរដាក់ថាភេទ "ប្រុស"
- ការចុះបញ្ជីដោយភាន់ច្រឡំលើថ្ងៃខែឆ្នាំកំណើតរបស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយ
- ខុសថ្ងៃកំណើតសុរិយគតិ ដូចជាថ្ងៃទី៣០ ខែកុម្ភៈ ឬថ្ងៃទី៣១ ខែមេសា
- ខុសថ្ងៃកំណើតចន្ទគតិ ដូចជាសរសេរចុះដាក់ថ្ងៃចន្ទ ទី១០ ខែតុលា ឆ្នាំ១៩៨៩ ប៉ុន្តែជាក់ស្ដែង ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៨៩ ជាថ្ងៃអង្គារ
- ការភាន់ច្រឡំទីតាំងភូមិសាស្ត្ររដ្ឋបាល ដូចជាសរសេរដាក់ថា ស្រុកអង្គរបុរី ខេត្តសៀមរាប ប៉ុន្តែ ជាក់ស្ដែងស្រុកអង្គរបុរី ស្ថិតនៅក្នុងខេត្តតាកែវ
- ខ្វង់ទីកន្លែងកំណើត បានសរសេរខុសពីទីកន្លែងកំណើតដែលសាមីខ្លួនបានកើតជាក់ស្ដែង ឬសរសេរ ខុសទីតាំងភូមិសាស្ត្ររដ្ឋបាលនាសម័យដែលបុគ្គលនោះកើត។ ឧទាហរណ៍ៈ បញ្ជីកំណើតរបស់បុគ្គល ម្នាក់បានចុះថាកើតឆ្នាំ១៩៨៥ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ប៉ុន្តែក្នុងអំឡុងឆ្នាំ១៩៨៥ ស្រុកមង្គលបុរី ស្ថិតនៅក្នុងខេត្តបាត់ដំបង ពីព្រោះនៅឆ្នាំ១៩៨៥ មិនទាន់បង្កើតខេត្តបន្ទាយមានជ័យ នៅឡើយ
- ការខកខានមិនបានចុះព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន លើកលែងតែការបន្ថែមទិន្នន័យ ព័ត៌មានណាដែលធ្វើឱ្យសាមីខ្លួនរួចផុតពីការទទួលខុសត្រូវខាងផ្លូវច្បាប់
- កែតម្រូវទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ។

**២. ការមោឃភាពបញ្ជីអត្រានុកូលដ្ឋាន**

ការមោឃភាពបញ្ជីអត្រានុកូលដ្ឋាន អាចធ្វើបានក្នុងករណីណាមួយដូចខាងក្រោមៈ
- ចុះបញ្ជីផ្ទុយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន
- ចុះខុសបែបបទ នីតិវិធីនៃការងារអត្រានុកូលដ្ឋាន
- ចុះបញ្ជីអត្រានុកូលដ្ឋានលើសពី ១ (មួយ) ដង នៅកន្លែងដដែល ឬនៅកន្លែងផ្សេងទៀត
- មោឃភាពលើបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ។

**II. សមត្ថកិច្ចក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន**

សមត្ថកិច្ចក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ត្រូវបានកំណត់ដូចខាងក្រោមៈ

១. នៅក្នុងឆ្នាំកំពុងអនុវត្ត ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានជាសមត្ថកិច្ចរបស់មន្ត្រី អត្រានុកូលដ្ឋានឃុំ សង្កាត់។ នៅក្នុងឆ្នាំកំពុងអនុវត្ត សំដៅដល់ការអនុវត្តការងារអត្រានុកូលដ្ឋានគ្រប់ ប្រភេទក្នុងឆ្នាំបច្ចុប្បន្ន (គិតពីថ្ងៃទី០១ ខែមករា មកទល់ថ្ងៃទី៣១ ខែធ្នូ) ដោយមិនទាន់ឆ្លងចូលឆ្នាំថ្មី។

២. នៅក្នុងឆ្នាំកន្លងផុត ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានជាសមត្ថកិច្ចរបស់មន្ត្រី អត្រានុកូលដ្ឋានថ្នាក់ជាតិ។ នៅក្នុងឆ្នាំកន្លងផុត សំដៅដល់ការអនុវត្តការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដែលកន្លងផុត ឬហួសឆ្នាំកំពុងអនុវត្ត ដូចបានចែងក្នុងចំណុចទី១ខាងលើ។

៣. ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដែលមិនមែនជាសមត្ថកិច្ចរបស់ មន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់ជាតិដូចបានកំណត់នៅក្នុងចំណុច "**I. អំពីទិន្នន័យដែលអាចកែតម្រូវបាន និងការមោឃភាពបញ្ជី អត្រានុកូលដ្ឋាន**" ខាងលើ ជាសមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចតាមច្បាប់កំណត់។

## III. នីតិវិធីក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

### ១. នៅក្នុងឆ្នាំកំពុងអនុវត្ត

ក្នុងករណីពិនិត្យឃើញថាសំបុត្រអត្រានុកូលដ្ឋានបានសរសេរព័ត៌មានមួយចំនួនខុស ឬមានកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជន ដែលមានឈ្មោះក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារជាមួយគ្នា អាចដាក់ពាក្យសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃទីតាំងដែលបានចុះបញ្ជី។ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន របស់អ្នកដាក់ពាក្យសុំស្របតាមនីតិវិធីដូចខាងក្រោម៖

#### ១.១. ការកែតម្រូវលើកំហុសទិន្នន័យដែលអាចកែតម្រូវបាន

បែបបទ នីតិវិធីនៃការកែតម្រូវលើកំហុសទិន្នន័យដែលអាចកែតម្រូវបាន ត្រូវបានកំណត់ដូចខាងក្រោម៖

- ត្រូវឆូតពាក្យដែលខុសទាំងនោះដោយ **ទឹកប៊ិកពណ៌ក្រហម** ដោយរក្សាទុកពាក្យខុសនោះនៅអាចមើលបាន
- សរសេរពាក្យដែលត្រឹមត្រូវ **នៅទន្ទឹម** ឬនៅ **ពីលើពាក្យដែលខុស** ទាំងនោះដោយទឹក **ប៊ិកពណ៌ខៀវ**
- សរសេរដោយទឹកប៊ិកពណ៌ក្រហម **នៅរឹមទំព័រខាងឆ្វេង** ថា "**យល់ព្រមលុបពាក្យ ... និងយល់ព្រមសរសេរពាក្យ ... ជំនួសវិញ**"។ អ្នករាយការណ៍ ឬសាមីខ្លួនត្រូវផ្តិតស្នាមមេដៃ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា បោះត្រាឈ្មោះ និងចុះកាលបរិច្ឆេទនៃការកែតម្រូវ
- មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញសំបុត្រអត្រានុកូលដ្ឋានថ្មី ជូនអ្នករាយការណ៍ ឬសាមីខ្លួន។

#### ១.២. ការមោឃភាពលើបញ្ជីអត្រានុកូលដ្ឋានដែលមិនអាចកែតម្រូវបាន

បែបបទ នីតិវិធីនៃការធ្វើមោឃភាពលើបញ្ជីអត្រានុកូលដ្ឋានដែលមិនអាចកែតម្រូវបាន ត្រូវបានកំណត់ដូចខាងក្រោម៖

- ក្នុងករណីបញ្ជីអត្រានុកូលដ្ឋានណាមួយដែលបំពេញខុស ហើយមិនអាចកែតម្រូវបាន ត្រូវទុកជាមោឃៈដោយសរសេរពាក្យ "**ទុកជាមោឃៈ**" ជាអក្សរធំៗដោយទឹកប៊ិកពណ៌ក្រហមនៅចំកណ្តាលបញ្ជីដែលទុកជាមោឃៈនោះ បន្ទាប់មកសរសេរចុះថ្ងៃ ខែ ឆ្នាំ និងចុះហត្ថលេខាមន្ត្រីអត្រានុកូលដ្ឋាន និងបោះត្រារបស់រដ្ឋបាលឃុំ សង្កាត់ ហើយរក្សាទុកជាឯកសារ
- បញ្ជីអត្រានុកូលដ្ឋានដែលទុកជាមោឃៈ មិនអនុញ្ញាតឱ្យហែកចោលឡើយ ហើយបញ្ជីអត្រានុកូលដ្ឋាននៅសន្លឹកបន្ទាប់ ត្រូវយកលេខរៀងដដែល។ ឧទាហរណ៍៖ បញ្ជីលេខ១៨ ទុកជាមោឃៈ ដូច្នេះបញ្ជីនៅសន្លឹកបន្ទាប់ ត្រូវចុះលេខ១៨ ដដែល
- បើមានបញ្ជីអត្រានុកូលដ្ឋានណាមួយទុកជាមោឃៈ បញ្ជីអត្រានុកូលដ្ឋាននៃសៀវភៅភ្លោះមួយក្បាលទៀតក៏ត្រូវទុកជាមោឃៈដែរ ដោយសរសេរថា *"ដោយសារបញ្ជីអត្រានុកូលដ្ឋានមួយក្បាលទៀតសរសេរខុសមិនអាចកែតម្រូវបាន ហើយទុកជាមោឃៈ"*។

២. នៅក្នុងឆ្នាំកន្លងផុត

២.១. ការដាក់ពាក្យ និងទីកន្លែងស្នើសុំ

សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលមានឈ្មោះក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារជាមួយគ្នា អាចដាក់ពាក្យទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីស្នើសុំកែតម្រូវទិន្នន័យ (ដូចមាននៅក្នុងឧបសម្ព័ន្ធទី១) ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន (ដូចមាននៅក្នុងឧបសម្ព័ន្ធទី២) នៅទីតាំងណាមួយដូចខាងក្រោម៖

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានរបស់សាមីខ្លួនបាននិងកំពុងរក្សាទុក ឬ
- នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

បន្ទាប់ពីទទួលពាក្យស្នើសុំ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារពាក់ព័ន្ធមករដ្ឋបាលរាជធានី ខេត្តយ៉ាងយូរ ៣ (បី) ថ្ងៃ នៃថ្ងៃការងារ។ រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារដែលទទួលបានពីរដ្ឋបាល ក្រុង ស្រុក ខណ្ឌ មកនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ យ៉ាងយូរ ៣ (បី) ថ្ងៃ នៃថ្ងៃការងារ។

២.២. ឯកសារភ្ជាប់

- សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម (ករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ត្រូវភ្ជាប់មកជាមួយនូវពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាល ឬពាក្យបណ្ដឹងនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម)
- បញ្ជីអត្រានុកូលដ្ឋានថតចម្លងដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ឬសញ្ញាបត្រ ឬវិញ្ញាបនបត្របញ្ជាក់ការសិក្សា។ល។

រាល់ឯកសារភ្ជាប់ត្រូវថតចម្លងដោយមានបញ្ជាក់នីត្យានុកូលកម្ម លើកលែងតែសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋាន។

២.៣. ការសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវធ្វើជាសេនាធិការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងការពិនិត្យលើទិដ្ឋភាពច្បាប់នៃឯកសារពាក់ព័ន្ធ និងមូលហេតុនៃការស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានដើម្បីធានាសង្គតិភាពទិន្នន័យអត្តសញ្ញាណបុគ្គលនីមួយៗ។ ក្នុងករណីចាំបាច់ នាយកដ្ឋានអត្រានុកូលដ្ឋាន ត្រូវសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីស្រាវជ្រាវបន្ថែមឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន រួចលើកយោបល់ជូនអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដែលជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ពិនិត្យសម្រេច។

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ អាចសម្រេចបដិសេធមិនឱ្យកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមការស្នើសុំបាន ដោយមានបញ្ជាក់អំពីមូលហេតុជាក់លាក់។ ករណីនេះ សាមីខ្លួនអាចដាក់ពាក្យស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ទៅតុលាការមានសមត្ថកិច្ចដើម្បីសុំការសម្រេច។

ក. ការសម្រេចកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវចេញសេចក្តីសម្រេចស្តីពីការកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន និងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមថ្មី ១ (មួយ) ច្បាប់ ដោយចុះកាលបរិច្ឆេទថ្មីទៅតាមពេលវេលាជាក់ស្តែងដែលចេញសំបុត្រអត្រានុកូលដ្ឋាននោះ រួចហើយដកហូត និងមោឃៈនូវសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមចាស់ និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានដែលខុសទាំងអស់។

ខ. ការមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវចេញសេចក្តីសម្រេចស្តីពីការមោឃភាពបញ្ជីអត្រានុកូលដ្ឋាន រួចហើយដកហូត និងមោឃៈសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមចាស់ និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានដែលខុសទាំងអស់។

គ. រយៈពេលនៃការសម្រេចកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

រាល់ការស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានត្រូវពិនិត្យសម្រេច៖

- មិនឱ្យលើសរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃការងារ ចំពោះពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានដែលដាក់នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង
- មិនឱ្យលើសរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃការងារ ចំពោះពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានដែលដាក់នៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- ករណីការស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានមិនមានឯកសារសម្អាងគ្រប់គ្រាន់ ដែលទាមទារការស្រាវជ្រាវបន្ថែមនោះ រយៈពេលនៃការសម្រេចលើករណីនីមួយៗអាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង។

ឃ. ការកំណត់ចំនួនសេចក្តីសម្រេចកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

សេចក្តីសម្រេចកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានត្រូវធ្វើឡើងចំនួន ៤ (បួន) ច្បាប់ ក្នុងនោះ៖

- ១ (មួយ) ច្បាប់ សម្រាប់រក្សាទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុក
- ១ (មួយ) ច្បាប់ សម្រាប់ចម្លងជូនរដ្ឋបាលរាជធានី ខេត្ត
- ១ (មួយ) ច្បាប់ សម្រាប់បញ្ជូនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុក
- ១ (មួយ) ច្បាប់ សម្រាប់សាមីខ្លួន។

២.៤. ការអនុវត្តសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

បន្ទាប់ពីទទួលបានសេចក្តីសម្រេចពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវ៖

- កិបភ្ជាប់សេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ នៅបញ្ជីអត្រានុកូលដ្ឋានដែលត្រូវធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

- ធ្វើការកែតម្រូវទិន្នន័យ ដោយឆូតទិន្នន័យដែលខុសដោយទឹកប៊ិកពណ៌ក្រហម និងសរសេរជួសនូវទិន្នន័យដែលត្រឹមត្រូវដោយទឹកប៊ិកពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវកែតម្រូវទិន្នន័យនោះដោយទឹកប៊ិកពណ៌ក្រហម (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៣)
- ធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដោយសរសេរទឹកប៊ិកពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវមោឃភាពនោះ (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៤)
- ចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ស្របតាមសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិចំនួន ៣ (បី) ច្បាប់។

## IV. នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ

### ១. នៅក្នុងឆ្នាំកំពុងអនុវត្ត

#### ១.១. ការដាក់ពាក្យ និងទីកន្លែងស្នើសុំ

បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់តុលាការ ក្នុងការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលមានឈ្មោះក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារជាមួយគ្នា អាចដាក់ពាក្យស្នើសុំ នៅរដ្ឋបាលឃុំ សង្កាត់ នៃទីតាំងដែលបានចុះបញ្ជីអត្រានុកូលដ្ឋាន (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៥)។

#### ១.២. ឯកសារភ្ជាប់

- សេចក្តីសម្រេចរបស់តុលាការ (ច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់នីត្យានុកូលកម្ម)
- សំបុត្រអត្រានុកូលដ្ឋានដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅរបស់អ្នកស្នើសុំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់អ្នកស្នើសុំ។

#### ១.៣. ការអនុវត្តសេចក្តីសម្រេចរបស់តុលាការនៅរដ្ឋបាលឃុំ សង្កាត់

បន្ទាប់ពីទទួលបានពាក្យស្នើសុំ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវអនុវត្តដូចខាងក្រោម៖

- ពិនិត្យផ្ទៀងផ្ទាត់បញ្ជីអត្រានុកូលដ្ឋាន ជាមួយនឹងសេចក្តីសម្រេចរបស់តុលាការ
- កិបភ្ជាប់សេចក្តីសម្រេចរបស់តុលាការ នៅលើបញ្ជីអត្រានុកូលដ្ឋានដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព
- កែតម្រូវទិន្នន័យ ដោយឆូតទិន្នន័យដែលខុសដោយទឹកប៊ិកពណ៌ក្រហម និងសរសេរជួសនូវទិន្នន័យដែលត្រឹមត្រូវដោយទឹកប៊ិកពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវកែតម្រូវទិន្នន័យនោះ ដោយទឹកប៊ិកពណ៌ក្រហម (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦)
- ធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដោយសរសេរទឹកប៊ិកពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវមោឃភាពនោះ (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៧)
- ដកហូតសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានចាស់ទាំងអស់ដែលតុលាការបានកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋានត្រូវបោះត្រាមោឃភាព និងរក្សាទុកនៅរដ្ឋបាលឃុំ សង្កាត់
- ចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន តាមបញ្ជីអត្រានុកូលដ្ឋានដែលបានកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានរួច ស្របតាមសេចក្តីសម្រេចរបស់តុលាការចំនួន ៣ (បី) ច្បាប់។

### ២. នៅក្នុងឆ្នាំកន្លងផុត

#### ២.១. ការដាក់ពាក្យ និងទីកន្លែងស្នើសុំ

បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់តុលាការ ក្នុងការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលមានឈ្មោះក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ជាមួយគ្នាអាចដាក់ពាក្យស្នើសុំនៅទីតាំងណាមួយ ដូចខាងក្រោម៖

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានរបស់សាមីខ្លួនបាននិងកំពុងរក្សាទុក (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៨) ឬ
- នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ (ដូចមាននៅក្នុង ឧបសម្ព័ន្ធទី៩)។

#### ២.២. ឯកសារភ្ជាប់

- សេចក្តីសម្រេចរបស់តុលាការ (ច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់នីត្យានុកូលកម្ម)
- សំបុត្រអត្រានុកូលដ្ឋានដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅរបស់អ្នកស្នើសុំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់ អ្នកស្នើសុំ។

#### ២.៣. ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ

#### ក. សមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋានពីអ្នកស្នើសុំ និង រដ្ឋបាលរាជធានី ខេត្ត មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យផ្ទៀងផ្ទាត់បញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុក ជាមួយនឹងសេចក្តីសម្រេចរបស់តុលាការ
- ថតចម្លងសេចក្តីសម្រេចរបស់តុលាការចំនួន ៥ (ប្រាំ) ច្បាប់ រួចបោះត្រាចូលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះ ១ (មួយ) ច្បាប់ សម្រាប់កិបភ្ជាប់ទៅនឹងបញ្ជីអត្រានុកូលដ្ឋាន ១ (មួយ) ច្បាប់ សម្រាប់ បញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ១ (មួយ) ច្បាប់ សម្រាប់បញ្ជូនទៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ១ (មួយ) ច្បាប់ សម្រាប់ជូនសាមីខ្លួន និង ១ (មួយ) ច្បាប់ សម្រាប់ បញ្ជូនទៅរដ្ឋបាលឃុំ សង្កាត់ ដើម្បីចេញសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមថ្មី
- កែតម្រូវទិន្នន័យ ដោយឆូតទិន្នន័យដែលខុសដោយទឹកប៊ិកពណ៌ក្រហម និងសរសេរជួសនូវទិន្នន័យ ដែលត្រឹមត្រូវដោយទឹកប៊ិកពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវ កែតម្រូវទិន្នន័យនោះដោយទឹកប៊ិកពណ៌ក្រហម (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៣)
- ធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដោយសរសេរទឹកប៊ិកពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងលើ បញ្ជីដែលត្រូវមោឃភាពនោះ (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៤)

- ដកហូតសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានចាស់ទាំងអស់ ដែលតុលាការបានកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន បន្ទាប់មកមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវបោះត្រា "មោឃៈ" រួចរក្សាទុកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន តាមបញ្ជីអត្រានុកូលដ្ឋានដែលបានកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានរួច ស្របតាមសេចក្តីសម្រេចរបស់តុលាការចំនួន ៣ (បី) ច្បាប់
- បញ្ជូនសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋានរបស់អ្នកស្នើសុំ មកនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម តាមរយៈរដ្ឋបាលរាជធានី ខេត្ត
- ក្នុងករណីការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការដែលបានទទួលពីនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មន្ត្រីរក្សាសៀវភៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ស្របតាមសេចក្តីសម្រេចរបស់តុលាការ។

**ខ. សមត្ថកិច្ចរបស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់តុលាការពីអ្នកស្នើសុំ ឬរដ្ឋបាលរាជធានី ខេត្ត នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យផ្ទៀងផ្ទាត់បញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុក ជាមួយនឹងសេចក្តីសម្រេចរបស់តុលាការ
- ថតចម្លងសេចក្តីសម្រេចរបស់តុលាការចំនួន ៤ (បួន) ច្បាប់ រួចបោះត្រាចូលរបស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្នុងនោះ ១ (មួយ) ច្បាប់ សម្រាប់កិបភ្ជាប់ទៅនឹងបញ្ជីអត្រានុកូលដ្ឋាន ១ (មួយ) ច្បាប់ សម្រាប់បញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ១ (មួយ) ច្បាប់ សម្រាប់បញ្ជូនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ១ (មួយ) ច្បាប់ សម្រាប់ជូនអ្នកស្នើសុំ
- កែតម្រូវទិន្នន័យ ដោយឆូតទិន្នន័យដែលខុសដោយទឹកប៊ិកពណ៌ក្រហម និងសរសេរជួសនូវទិន្នន័យដែលត្រឹមត្រូវដោយទឹកប៊ិកពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវកែតម្រូវទិន្នន័យនោះដោយទឹកប៊ិកពណ៌ក្រហម (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៣)
- ធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដោយសរសេរទឹកប៊ិកពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវមោឃភាពនោះ (ដូចមាននៅក្នុងឧបសម្ព័ន្ធទី៤)
- ដកហូតសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានចាស់ទាំងអស់ ដែលតុលាការបានកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន បន្ទាប់មកមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវបោះត្រាមោឃៈ រួចរក្សាទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន
- ចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន តាមបញ្ជីអត្រានុកូលដ្ឋានដែលបានកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានរួច ស្របតាមសេចក្តីសម្រេចរបស់តុលាការចំនួន ៣ (បី) ច្បាប់
- បញ្ជូនសេចក្តីសម្រេចរបស់តុលាការ ពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋានរបស់អ្នកស្នើសុំទៅ រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈរដ្ឋបាលរាជធានី ខេត្ត

- នាយកដ្ឋានអគ្រានុកូលដ្ឋានត្រូវលើកយោបល់ជូនមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ជាតិ ពិនិត្យសម្រេចចេញសំបុត្រអគ្រានុកូលដ្ឋានថ្មី។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយក នៃអគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ប្រធានស្ថាប័ន/អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តសេចក្តីណែនាំនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១២រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................. កើតថ្ងៃទី......... ខែ......... ឆ្នាំ.............. មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ.............. ក្រុមទី........... ភូមិ.......................... ឃុំ/សង្កាត់..................................... ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត.......................... ត្រូវជា(១) ..............................។

**សូមគោរពជូន**
**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
**និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ**

**កម្មវត្ថុ** : សំណើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន...........................................................។

**យោង** : (២)..........................................................................................................
..........................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាជ្រាបថា សំបុត្រអត្រានុកូលដ្ឋាន......................... របស់ឈ្មោះ.............................. ភេទ...... កើតថ្ងៃទី...... ខែ.......... ឆ្នាំ........... និងរបស់ឈ្មោះ.............................. ភេទ...... កើតថ្ងៃទី...... ខែ............ ឆ្នាំ............ ត្រង់បញ្ជីលេខ.............. នៅក្នុងសៀវភៅលេខ......... ឆ្នាំ........... ដែលបានចុះហត្ថលេខាដោយលោក/លោកស្រី.................................... ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់.................. ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត......................... មានកំហុសឆ្គងទិន្នន័យដែលមិនអាចប្រើប្រាស់បាន។

ដូចនេះខ្ញុំបាទ/នាងខ្ញុំ គោរពស្នើសុំធ្វើការកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានដូចខាងក្រោម ត្រង់៖

ខ្ទង់..................... របស់.................... ពី............................ ទៅ..............................
ខ្ទង់..................... របស់.................... ពី............................ ទៅ..............................
ខ្ទង់..................... របស់.................... ពី............................ ទៅ..............................
ខ្ទង់..................... របស់.................... ពី............................ ទៅ..............................
ខ្ទង់..................... របស់.................... ពី............................ ទៅ.............................. ជំនួសវិញ។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងទទួលខុសត្រូវនូវរាល់ព្យសនកម្មនានា ដែលកើតឡើងពីការសុំកែតម្រូវខាងលើនេះចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាធ្វើការកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ.................... ខែ.................. ឆ្នាំ......... ស័ក ព.ស.២៥...
ធ្វើនៅ.................... ថ្ងៃទី......... ខែ........... ឆ្នាំ២០...
ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

លេខ: .....................
បានឃើញ និងបញ្ជាក់ថាស្នាមមេដៃខាងស្តាំនេះពិតស្នាមមេដៃ
របស់ឈ្មោះ.............................. ពិតប្រាកដមែន។
ថ្ងៃ.................... ខែ.................. ឆ្នាំ......... ស័ក ព.ស.២៥...
ធ្វើនៅ.................... ថ្ងៃទី......... ខែ........... ឆ្នាំ២០...
**ប្រធាននាយកដ្ឋាន/អភិបាលក្រុង ស្រុក ខណ្ឌ**

កំណត់ចំណាំ:

(១) ត្រូវជាសាមីខ្លួន អាណាព្យាបាល ឬញាតិ
(២) ឯកសារដូចមាននៅខាងខ្នងនៃពាក្យស្នើសុំ

សំណុំឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយរួមមាន៖

- សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម (ករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ត្រូវភ្ជាប់មកជាមួយនូវពាក្យបណ្ដឹងពីប៉ុស្តិ៍នគរបាលរដ្ឋបាល)
- បញ្ជីអត្រានុកូលដ្ឋានថតចម្លងដែលត្រូវកែតម្រូវទិន្នន័យ
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ឬសញ្ញាបត្រ ឬ វិញ្ញាបនបត្របញ្ជាក់ការសិក្សា។ល។

រាល់ឯកសារខាងលើនេះ ត្រូវថតចម្លងដោយមានបញ្ជាក់នីត្យានុកូលកម្ម លើកលែងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានទាំងអស់។

ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................. កើតថ្ងៃទី......... ខែ......... ឆ្នាំ.............. មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ............ ក្រុមទី........... ភូមិ......................... ឃុំ/សង្កាត់.................................... ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត......................... ត្រូវជា[១] ...............................។

**សូមគោរពជូន**
**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
**និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ**

**កម្មវត្ថុ** : សំណើសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋាន.......................................។
**យោង** : [២]..........................................................................................................
..........................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាជ្រាបថា សំបុត្រអត្រានុកូលដ្ឋាន...................... របស់ឈ្មោះ........................... ភេទ...... កើតថ្ងៃទី...... ខែ........... ឆ្នាំ........... បានចុះបញ្ជីចំនួន .......... ដង មានដូចខាងក្រោម៖

ចុះបញ្ជីលើកទី១ ត្រង់បញ្ជីលេខ........... នៅក្នុងសៀវភៅលេខ..... .......... ឆ្នាំ..... ......... នៅក្នុងឃុំ/សង្កាត់ ............................ ក្រុង/ស្រុក/ខណ្ឌ..................................... រាជធានី/ខេត្ត..........................................

ចុះបញ្ជីលើកទី២ ត្រង់បញ្ជីលេខ........... នៅក្នុងសៀវភៅលេខ..... .......... ឆ្នាំ..... ......... នៅក្នុងឃុំ/សង្កាត់ ............................ ក្រុង/ស្រុក/ខណ្ឌ..................................... រាជធានី/ខេត្ត..........................................

ចុះបញ្ជីលើកទី៣ ត្រង់បញ្ជីលេខ........... នៅក្នុងសៀវភៅលេខ..... .......... ឆ្នាំ..... ......... នៅក្នុងឃុំ/សង្កាត់ ............................ ក្រុង/ស្រុក/ខណ្ឌ..................................... រាជធានី/ខេត្ត..........................................

ដែលផ្ទុយនឹងមាត្រា ៦៣ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន។

ផ្អែកលើកំហុសឆ្គងខាងលើ ខ្ញុំបាទ/នាងខ្ញុំ ស្នើសុំធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានដែលបានចុះលើកទី...... និងសុំរក្សាទុកបញ្ជីអត្រានុកូលដ្ឋានដែលបានចុះលើកទី......... ដើម្បីប្រើប្រាស់ជាផ្លូវការ។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងទទួលខុសត្រូវនូវរាល់ព្យសនកម្មនានា ដែលកើតឡើងពីការធ្វើមោឃភាពខាងលើនេះចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាពិនិត្យសម្រេចមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ.................... ខែ................. ឆ្នាំ......... ស័ក ព.ស.២៥...
ធ្វើនៅ.................... ថ្ងៃទី......... ខែ........... ឆ្នាំ២០...
**ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ**

លេខ: ..................
បានឃើញ និងបញ្ជាក់ថាស្នាមមេដៃខាងស្តាំនេះពិតស្នាមមេដៃ
របស់ឈ្មោះ.................................. ពិតប្រាកដមែន។
ថ្ងៃ.................... ខែ................. ឆ្នាំ......... ស័ក ព.ស.២៥...
ធ្វើនៅ.................... ថ្ងៃទី......... ខែ........... ឆ្នាំ២០...
**ប្រធាននាយកដ្ឋាន/អភិបាលក្រុង ស្រុក ខណ្ឌ**

<u>កំណត់ចំណាំ:</u>

[១] ត្រូវជាសាមីខ្លួន អាណាព្យាបាល ឬញាតិ
[២] ឯកសារដូចមាននៅខាងខ្នងនៃពាក្យស្នើសុំ

សំណុំឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយរួមមាន៖

- សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម (ករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ត្រូវភ្ជាប់មកជាមួយនូវពាក្យបណ្ដឹងពីប៉ុស្ដិ៍នគរបាលរដ្ឋបាល)
- បញ្ជីអត្រានុកូលដ្ឋានថតចម្លងដែលត្រូវមោឃភាព និង/ឬរក្សាទុក
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ឬសញ្ញាបត្រ ឬវិញ្ញាបនបត្របញ្ជាក់ការសិក្សា។ល។

រាល់ឯកសារខាងលើនេះ ត្រូវថតចម្លងដោយមានបញ្ជាក់នីត្យានុកូលកម្ម លើកលែងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានទាំងអស់។

ឧបសម្ព័ន្ធទី៣

បញ្ជីអត្រានុកូលដ្ឋាននេះបានកែតម្រូវ

យោង..............លេខ...........ចុះថ្ងៃទី.....ខែ...........ឆ្នាំ........របស់.......................។

ថ្ងៃទី........ខែ...........ឆ្នាំ........

មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី៤

បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព

យោង..............លេខ............ចុះថ្ងៃទី.....ខែ...........ឆ្នាំ........របស់.....................។

ថ្ងៃទី........ខែ...........ឆ្នាំ........

មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី៥

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចរបស់តុលាការ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ........................... កើតថ្ងៃទី........ ខែ........ ឆ្នាំ.............មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ.......... ផ្លូវ............. ក្រុមទី.......... ភូមិ.....................ឃុំ/សង្កាត់........................................ ក្រុង/ស្រុក/ខណ្ឌ.....................រាជធានី/ខេត្ត.....................ត្រូវជា[១] ..........................។

## សូមគោរពជូន
### មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់...................

**កម្មវត្ថុ** : សំណើសុំ ☐កែតម្រូវទិន្នន័យ ☐មោឃភាពបញ្ជីអត្រានុកូលដ្ឋាន....................តាមសេចក្តីសម្រេចរបស់តុលាការ។

**យោង** : [២]....................................................................................................

............................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **លោក លោកស្រី មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់** មេត្តាជ្រាបថា សេចក្តីសម្រេចលេខ.....................ចុះថ្ងៃទី........ខែ........ឆ្នាំ...........របស់តុលាការ .....................បានសម្រេច ☐កែតម្រូវទិន្នន័យ ☐មោឃភាពបញ្ជីអត្រានុកូលដ្ឋាន.........................របស់ឈ្មោះ.........................ភេទ.....កើតថ្ងៃទី.....ខែ.........ឆ្នាំ.........និងរបស់ឈ្មោះ..................... ភេទ.....កើតថ្ងៃទី.....ខែ.......ឆ្នាំ..........ត្រង់បញ្ជីលេខ..........នៅក្នុងសៀវភៅលេខ.......ឆ្នាំ..........ដែលបានចុះហត្ថលេខាដោយលោក/លោកស្រី...........................ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់.......................... ក្រុង/ស្រុក/ខណ្ឌ.....................រាជធានី/ខេត្ត...........................។

អាស្រ័យហេតុនេះ សូម **លោក លោកស្រី មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់** មេត្តាធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពទិន្នន័យ បញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ..................ខែ...............ឆ្នាំ........ស័ក ព.ស.២៥...

ធ្វើនៅ.................. ថ្ងៃទី........ ខែ.......... ឆ្នាំ២០...

ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

<u>កំណត់ចំណាំ:</u>

[១] ត្រូវជាសាមីខ្លួន អាណាព្យាបាល ឬញាតិ

[២] ឯកសារដូចមាននៅខាងខ្នងនៃពាក្យស្នើសុំ

សំណុំឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយរួមមាន៖

- សេចក្ដីសម្រេចរបស់តុលាការ ( ច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់នីត្យាកូលកម្ម)
- សំបុត្រអត្រានុកូលដ្ឋានដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅរបស់អ្នកស្នើសុំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់អ្នកស្នើសុំ។

ឧបសម្ព័ន្ធទី៦

បញ្ជីអត្រានុកូលដ្ឋាននេះបានកែតម្រូវ

យោង..............លេខ...........ចុះថ្ងៃទី.....ខែ...........ឆ្នាំ........របស់.......................។

ថ្ងៃទី........ខែ...........ឆ្នាំ........

មន្ត្រីអត្រានុកូលដ្ឋាន

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី៧

បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព

យោង..............លេខ............ចុះថ្ងៃទី.....ខែ...........ឆ្នាំ.........របស់.......................។

ថ្ងៃទី.........ខែ...........ឆ្នាំ.........

មន្ត្រីអត្រានុកូលដ្ឋាន

ហត្ថលេខានិងឈ្មោះ

ឧបសម្ព័ន្ធទី៨

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចរបស់តុលាការ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................. កើតថ្ងៃទី......... ខែ......... ឆ្នាំ.............. មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ............. ក្រុមទី........... ភូមិ.......................... ឃុំ/សង្កាត់.......................................... ក្រុង/ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត...................... ត្រូវជា(១) ............................។

**សូមគោរពជូន**

**អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ.....................**

**កម្មវត្ថុ** : សំណើសុំ □កែតម្រូវទិន្នន័យ □មោឃភាពបញ្ជីអត្រានុកូលដ្ឋាន...................... តាមសេចក្តីសម្រេចរបស់តុលាការ។

**យោង** : (២)....................................................................................................................
.................................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **លោក លោកស្រី អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា សេចក្តីសម្រេចលេខ...................... ចុះថ្ងៃទី......... ខែ......... ឆ្នាំ........... របស់តុលាការ........................ បានសម្រេច □កែតម្រូវទិន្នន័យ □មោឃភាពបញ្ជីអត្រានុកូលដ្ឋាន .................... របស់ឈ្មោះ................................ ភេទ...... កើតថ្ងៃទី...... ខែ........... ឆ្នាំ........... និងរបស់ឈ្មោះ.............................. ភេទ...... កើតថ្ងៃទី...... ខែ........... ឆ្នាំ.................. ត្រង់បញ្ជីលេខ........... នៅក្នុងសៀវភៅលេខ......... ឆ្នាំ........... ដែលបានចុះហត្ថលេខាដោយលោក/លោកស្រី.......................... ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់ .................... ក្រុង/ស្រុក/ខណ្ឌ...................... រាជធានី/ខេត្ត......................។

អាស្រ័យហេតុនេះ សូម **លោក លោកស្រី អភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ.................... ខែ................ ឆ្នាំ......... ស័ក ព.ស.២៥...

ធ្វើនៅ.................. ថ្ងៃទី......... ខែ........... ឆ្នាំ២០...

ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

<u>កំណត់ចំណាំ:</u>

(១) ត្រូវជាសាមីខ្លួន អាណាព្យាបាល ឬញាតិ

(២) ឯកសារដូចមាននៅខាងខ្នងនៃពាក្យស្នើសុំ

សំណុំឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយរួមមាន៖

- សេចក្តីសម្រេចរបស់តុលាការ ( ច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់នីត្យាកូលកម្ម)
- សំបុត្រអត្រានុកូលដ្ឋានដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅរបស់អ្នកស្នើសុំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់អ្នកស្នើសុំ។

ឧបសម្ព័ន្ធទី៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន
## តាមសេចក្តីសម្រេចរបស់តុលាការ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................. កើតថ្ងៃទី......... ខែ......... ឆ្នាំ.............. មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ.............. ក្រុមទី........... ភូមិ.......................ឃុំ/សង្កាត់....................................... ក្រុង/ស្រុក/ខណ្ឌ.......................រាជធានី/ខេត្ត.......................ត្រូវជា(១) ..............................។

## សូមគោរពជូន
## ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
## និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

**កម្មវត្ថុ** : សំណើសុំ □កែតម្រូវទិន្នន័យ □មោឃភាពបញ្ជីអត្រានុកូលដ្ឋាន.......................តាមសេចក្តីសម្រេចរបស់តុលាការ។

**យោង** : (២)......................................................................................................................

......................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាជ្រាបថា សេចក្តីសម្រេចលេខ.......................ចុះថ្ងៃទី.........ខែ.........ឆ្នាំ..............របស់តុលាការ ..............................បានសម្រេច □កែតម្រូវទិន្នន័យ □មោឃភាពបញ្ជីអត្រានុកូលដ្ឋាន.......................របស់ឈ្មោះ ..............................ភេទ......កើតថ្ងៃទី......ខែ...........ឆ្នាំ........ និងរបស់ឈ្មោះ..............................ភេទ......កើតថ្ងៃទី......ខែ.........ឆ្នាំ...........ត្រង់បញ្ជីលេខ.........នៅក្នុងសៀវភៅលេខ.........ឆ្នាំ...........ដែលបានចុះហត្ថលេខាដោយលោក/លោកស្រី.......................ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់....................ក្រុង/ស្រុក/ខណ្ឌ.......................រាជធានី/ខេត្ត.......................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ....................ខែ..................ឆ្នាំ.........ស័ក ព.ស.២៥...

ធ្វើនៅ....................ថ្ងៃទី.........ខែ...........ឆ្នាំ២០...

ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

លេខៈ .................

បានឃើញ និងបញ្ជាក់ថាស្នាមមេដៃខាងស្តាំនេះពិតស្នាមមេដៃ របស់ឈ្មោះ.................................. ពិតប្រាកដមែន។

ថ្ងៃ....................ខែ..................ឆ្នាំ.........ស័ក ព.ស.២៥...

ធ្វើនៅ....................ថ្ងៃទី.........ខែ...........ឆ្នាំ២០...

**ប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន**

<u>កំណត់ចំណាំ:</u>

(១) ត្រូវជាសាមីខ្លួន អាណាព្យាបាល ឬញាតិ

(២) ឯកសារដូចមាននៅខាងខ្នងនៃពាក្យស្នើសុំ

សំណុំឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយរួមមាន៖

- សេចក្តីសម្រេចរបស់តុលាការ (ច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់នីត្យាកូលកម្ម)
- សំបុត្រអត្រានុកូលដ្ឋានដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅរបស់អ្នកស្នើសុំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់អ្នកស្នើសុំ។